ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ..១៣១៣៣....អពដ

L20200609001 | TD3144

ថ្ងៃ អង្គារ ១០ កើត ខែ អាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែ មិថុនា ឆ្នាំ២០២០

# សេចក្តីជូនដំណឹង

## ស្តីពី

## ការផ្តល់សេវាពន្ធដារលើការប្រគល់ប័ណ្ណសម្គាល់ការបង់ពន្ធមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ នៅតាមសាខាពន្ធដារខេត្ត-ខណ្ឌ និងធនាគារពាណិជ្ជ

អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ម្ចាស់យានយន្តទាំងអស់ឱ្យបានជ្រាបថា អគ្គនាយកដ្ឋានពន្ធដារបានបោះពុម្ពប័ណ្ណសម្គាល់ការបង់ពន្ធមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ តាមការស្នើសុំរបស់ម្ចាស់យានយន្តដែលបានបង់កម្រៃសេវា ៥ ០០០រៀល រួចរាល់ និងបានធ្វើការប្រគល់ជូនម្ចាស់យានយន្តបានមួយចំនួន។ ចំណែកម្ចាស់យានយន្តមួយចំនួនទៀតពុំទាន់ទទួលបានប័ណ្ណនៅឡើយ ដោយមូលហេតុពុំអាចធ្វើការទំនាក់ទំនងម្ចាស់យានយន្តបាន និងពុំទាន់អញ្ជើញមកទទួលយកប័ណ្ណសម្គាល់នេះពីសាខាពន្ធដារខេត្ត-ខណ្ឌ ឬធនាគារពាណិជ្ជដែលបានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

ដូចនេះ ដើម្បីសម្រួលដល់ការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទប្រចាំឆ្នាំ អគ្គនាយកដ្ឋានពន្ធដារ សូមជូនដំណឹងដល់ម្ចាស់យានយន្តទាំងអស់ដែលបានស្នើសុំប័ណ្ណសម្គាល់ការបង់ពន្ធមធ្យោបាយ អញ្ជើញមកទទួលយកប័ណ្ណសម្គាល់នេះនៅរៀងរាល់ម៉ោងធ្វើការនៅសាខាពន្ធដារខេត្ត-ខណ្ឌ ឬធនាគារពាណិជ្ជដែលលោក-អ្នកបានស្នើសុំធ្វើប័ណ្ណសម្គាល់ខាងលើ និងសូមផ្តល់នូវព័ត៌មានមួយចំនួនដូចជា បង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធចុងក្រោយ (ថតចម្លង) ឬប័ណ្ណសម្គាល់យានយន្ត (ច្បាប់ដើម) ដើម្បីរដ្ឋបាលសារពើពន្ធងាយស្រួលស្វែងរកប័ណ្ណសម្គាល់ការបង់ពន្ធមធ្យោបាយជូនបានឆាប់រហ័ស។

ចំពោះម្ចាស់យានយន្តដែលពុំទាន់បានស្នើសុំប័ណ្ណសម្គាល់ការបង់ពន្ធមធ្យោបាយ សូមអញ្ជើញមកបំពេញពាក្យស្នើសុំ និងបង់កម្រៃសេវា ៥ ០០០ រៀល នៅតាមសាខាពន្ធដារខេត្ត-ខណ្ឌដែលនៅជិតលោកអ្នក ដើម្បីធ្វើការបោះពុម្ពប័ណ្ណសម្គាល់ការបង់ពន្ធមធ្យោបាយជូនភ្លាមៗ។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកកាន់សាខាពន្ធដារខេត្ត-ខណ្ឌដែលនៅជិតលោកអ្នក ឬតាមរយៈទូរស័ព្ទលេខ ១២៧៧។

អគ្គនាយកដ្ឋានពន្ធដារ

អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី (១១០) និង ម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855)23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh